00803410

002/19-09-2007-ECCC/TC
E1/58

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 04 / 2012
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ ទី ០៣ ខែ មេសា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្ដី - ថ្ងៃទី ៤៦

**រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS**

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Roger PHILLIPS, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH, លោក Dale LYSAK |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT លោក Barnabé NEKUIE, លោក វ៉ែន ពៅ, លោក ហុង គីមសួន, លោកស្រី ម៉ុច សុវណ្ណារី, លោកស្រី ជេត វណ្ណលី, លោកស្រី Lyma NGUYEN, លោកស្រី Marie GUIRAUD |
| សាក្សី៖ កាំង ហ្កេកអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Zuzana KOVALOVA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃអង្គារ ទី០៣ ខែមេសា ឆ្នាំ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖១០.៣៥ | បញ្ចប់ម៉ោង៖ ១១.១០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៤០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៣០ | បញ្ចប់ម៉ោង៖ ១៤.៥០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៤ ម៉ោង និង ២៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការតាំងសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា | ៩.០៥<br>១១.១៥<br>១៥.០០ | ១០.៣៥<br>១៤.៣០<br>១៦.០០ |
| សំណើសុំពេលវេលាបន្ថែម | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ០៩.៥៥ | ០៩.៥៥ |
| ការបញ្ជាក់អំពីការប្រើប្រាស់សេចក្តីថ្លែងការណ៍របស់សាក្សីដែលបានធ្វើពីពេលមុន និងប្រតិចារឹកក្នុងសំណុំរឿង ០០១ | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ១០.១០<br>១៤.៥៥ | ១១.២០<br>១៥.០០ |

00803412



| | | | |
|---|---|---|---|
| | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | | |
| ការស្នើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ១០.៣១<br>១២.០២ | ១០.៣២<br>១២.០៣ |
| សំណើសុំធ្វើការឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សី (ដោយ នួន ជា) | មេធាវីការពារក្តី នួន ជា | ១៥.០០ | ១៥.០០ |
| សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១៥.១៥ | ១៥.៣៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការសាកសួរសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច**

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់ការសួរសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច ។ បន្ទាប់មក អង្គជំនុំជម្រះ (ចៅក្រម Lavergne និងលោកប្រធាន) សួរសំណួរមួយចំនួនដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច ។ មេធាវីការពារក្តី នួន ជា ចាប់ផ្តើមការសួរសំណួរដល់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច ។

**សំណើសុំពេលវេលាបន្ថែម**

អង្គជំនុំជម្រះបានសម្រេចផ្តល់ពេលវេលាបន្ថែមដល់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២ នាទី បន្ថែមទៀតសម្រាប់ការសួរសំណួរដល់សាក្សី ។

**ការបញ្ជាក់អំពីការប្រើប្រាស់សេចក្តីថ្លែងការណ៍របស់សាក្សីដែលបានធ្វើពីពេលមុន និងប្រតិចារឹកក្នុងសំណុំរឿង០០១**

អង្គជំនុំជម្រះបានបញ្ជាក់ថា រាល់កំណត់ហេតុស្តាប់ចម្លើយរបស់ កាំង ហ្កេចអ៊ាវ ហៅ ឌុច ដែលបានធ្វើដោយសហចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលនៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០២ ឬក្នុងអំឡុងពេលនៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០១ ហើយដែលបានដាក់ចូលក្នុងសំណុំរឿង ០០២ គឺចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ចំពោះប្រតិចារឹកក្នុងសំណុំរឿង ០០១ ភាគីអាចដាក់នូវផ្នែកដែលពាក់ព័ន្ធ ប៉ុន្តែត្រូវចង្អុលឱ្យបានច្បាស់លាស់ នូវចំណុចដែលភាគីមានបំណងយកមកប្រើប្រាស់ជាមូលដ្ឋានក្នុងការសួរសំណួរ ។ អង្គជំនុំជម្រះរំឭកឡើងវិញនូវសេចក្តីសម្រេចរបស់ខ្លួនត្រង់កថាខណ្ឌ ៤ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះ (ឯកសារE172/5) ទាក់ទងនឹងឯកសារដែលបានភ្ជាប់ទៅនឹងកំណត់ហេតុជាលាយលក្ខអក្សរណ៍នៃការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ។

**ការស្នើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើ (លិខិតលះបង់សិទ្ធិត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ) ។

**សំណើសុំធ្វើការឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សី (ដោយ នួន ជា)**

ជនជាប់ចោទ នួន ជា ស្នើសុំពេលវេលាចំនួនប្រាំនាទី (០៥) មុនពេលចាប់ផ្តើមសវនាការថ្ងៃបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សី ។

**សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី**

បន្ទាប់ពីសហព្រះរាជអាជ្ញាជំទាស់ទៅនឹងសំណួរ ដែលបានសួរដោយក្រុមមេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះសម្រេចអំពីសិទ្ធិនៅស្ងៀម និងសិទ្ធិមិនឆ្លើយតបទៅនឹងសំណួរដែលអាចឈានដល់ការដាក់បន្ទុកមកលើសាក្សី ។ លោកប្រធានក៏បានបញ្ជាក់ផងដែរថា សាក្សីមានសិទ្ធិក្នុងការសម្រេច ថាតើត្រូវឆ្លើយតប ឬមិនឆ្លើយតបទៅនឹងសំណួរ ដែលទាក់ទងនឹងអង្គហេតុដែលបានជំនុំជម្រះរួចហើយ ។

Record of Rule 87(3) Proceedings

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1556 | D229.1 | 00285361-00285393 | របាយការណ៍សរុបរបស់មន្ទីរ ស២១ ផែនការចុងក្រោយរបស់ ស២១ | P | | | |
| E3/527 | D288/6.5/2.29 | 00238901-00238909, 00069031-00069057 00314947-00314973 | The last joint plan Le dernier plan conjoint | P | | | |
| N/A | E1/51.1 | 00791903-00791975 00792960-00793045 00793046-00793136 | ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ - ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ Transcript of hearing on the substance in Case 002 - 20 March 2012 Transcript of hearing on the substance in Case 002 - 20 March 2012 | P | | 00792996, 00792965 | 00793084, 00793052 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/189 | D108 /43/3 | 00323157-00323163 00179652-00179655 00186604-00186609 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ឧបសម្ព័ន្ធ៣:លិខិតចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៥ ពីតំណាងអចិន្ត្រៃយ៍ របស់ចិនប្រចាំអង្គការសហប្រជាជាតិ ជូនចំពោះអគ្គលេខាធិការ<br><br>[Surrogate Sheet] Annex 3: Letter dated 20 March 1975 from the Permanent Representative of China to the United Nations addressed to the Secretary-General dated 20 March 1975 [Feuille remplacée] Annex 3: Letter dated 20 March 1975 from the Permanent Representative of China to the United Nations addressed to the Secretary-General, en date du 20 mars 1975 | P | | | 00186607, 00186608 |
| E3/833 | 14.3 | 00077661-00078056 00242259-00242263, 00184579-00184618 00282468-00282547, 00373110-00373115 | កំណត់ហេតុរបស់ ចាន់ ជាភាសាខ្មែរ ចុះថ្ងៃទី១៧ធ្នូ១៩៧៧<br><br>S-21 Notebook by MAM Nai alias Chan<br><br>[Corrigé 1] S-21 Livre de Mam Nai alias Chan | P | 00077896 | 00184608 | |
| E3/1557 | D366 /7.1.96 | 00076349-00076373 00768111-00768131 00782159-00782176 | ស២១ ចំលើយសារភាពរបស់ ឡាច វ៉ារី ហៅ ណាន (ក្មួយស្រីរបស់ នួន ជា, អនុប្រធានរបស់ អៀង ធិរិទ្ធ)<br>S-21 Confession of LACH Vary alias Nan (Nuon Chea's niece, Thirith's deputy)<br><br>Aveux de LACH Vary alias NAN (nièce de NUON CHEA, assistante de Thirith) | P | | | |
| E3/12 | 6.3 | 00003136-00003142, 00000758-00000764 00182809-00182814 00224363-00224367 | សេចក្ដីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន<br><br>Decision of central committee on a number of problems Decision of central committee on a number of problems | P | | | |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.៣២) និង នួន ជា (ម៉ោង ១២.០៣) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ ។
- សេចក្ដីសម្រេចទាក់ទងនឹងការដាក់នូវកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់សាក្សី កាំង ហ្កេចអ៊ាវ ហៅ ឌុច៖

អង្គជំនុំជម្រះសូមបញ្ជាក់ថាកំណត់ជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ កាំង ហ្កេកអ៊ាវ ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងអំឡុងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ឬក្នុងអំឡុងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០១ និងដែលត្រូវបានដាក់ក្នុងសំណុំរឿង ០០២ ត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ មិនគិតថាតើកំណត់ហេតុ ជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយទាំងនោះត្រូវបានលើកមកពិភាក្សានៅក្នុងសវនាការឡើយ ឯកសារទាំងអស់នេះត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះទាំងស្រុង ហើយអាចជាមូលដ្ឋានសម្រាប់ការសួរសំណួរទៅសាក្សីរូបនេះ។

ទាក់ទិននឹងប្រតិចារឹកពីសំណុំរឿង ០០១ ភាគីអាចដាក់ចំពោះមុខអង្គជំនុំជម្រះនូវផ្នែកពាក់ព័ន្ធនៃប្រតិចារឹក ប៉ុន្តែត្រូវបញ្ជាក់ឱ្យបានច្បាស់នូវផ្នែកទាំងឡាយដែលខ្លួនមានបំណងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការសួរសំណួរ។

- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ០៤ ខែ មេសា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី០៣ ខែ មេសា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារី Roger PHILLIPS